ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

*ថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥*
*ខេត្តសៀមរាប ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២*

# សេចក្ដីប្រកាសព័ត៌មាន

នាថ្ងៃពុធ ៤ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២ នៅសណ្ឋាគារសោមាទេវីអង្គរ ខេត្តសៀមរាប **ឯកឧត្តម ឈឿង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាប្រធានគណៈកម្មាធិការដឹកនាំការងារថ្នាក់ជាតិ បានដឹកនាំកិច្ចប្រជុំរបស់គណៈកម្មាធិការដឹកនាំការងារថ្នាក់ជាតិសម្រាប់កម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដំណាក់កាលទី៤ (Regional Economic Development Program Phase IV - RED IV) និងប្រកាសឱ្យដំណើរការគម្រោង "ការលើកកម្ពស់ភាពប្រកួតប្រជែងរបស់សហគ្រាសនៅកម្ពុជា" ។ កិច្ចប្រជុំនេះ មានការចូលរួមពីលោកជំទាវ ឯកឧត្តម លោក លោកស្រី ជាតំណាងមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធចំនួន ៩, តំណាងរដ្ឋបាលខេត្តសៀមរាប, បន្ទាយមានជ័យ, បាត់ដំបង, ឧត្តរមានជ័យ, ព្រះវិហារ តំណាងទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការ (SDC), ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (GIZ) និងមន្ត្រីកម្មវិធី RED IV សរុបប្រមាណ ៣៥ រូប ។ គោលបំណងចម្បងនៃកិច្ចប្រជុំនេះ គឺដើម្បីពិនិត្យ និងអនុម័តលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធី RED IV ក្នុងឆ្នាំ២០២១-២០២២ ក្នុងខេត្តគោលដៅទាំង៤ (សៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ និងព្រះវិហារ) ព្រមទាំងប្រកាសឱ្យដំណើរការជាផ្លូវការគម្រោង "ការលើកកម្ពស់ភាពប្រកួតប្រជែងរបស់សហគ្រាសនៅកម្ពុជា" ។

អង្គប្រជុំ បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផល ដែលកម្មវិធី RED IV សម្រេចបានក្នុងរយៈពេល ២ឆ្នាំ កន្លងមកនេះ ជាពិសេសក្នុងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ។ កម្មវិធី RED IV ក្រោមការគាំទ្រហិរញ្ញប្បទានពីប្រទេសអាល្លឺម៉ង់ និងប្រទេសស្វីស ព្រមទាំងថវិកាបដិភាគរាជរដ្ឋាភិបាលកម្ពុជា សរុបចំនួន ៨,៤១ លានអឺរ៉ូ ជាលទ្ធផល កម្មវិធីបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ក្នុងខេត្តគោលដៅទាំង ៤ ។ គួររំឭកផងដែរថា កម្មវិធីនេះបានចាប់ផ្ដើមអនុវត្តចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២១ ប៉ុន្តែត្រូវបានពន្យាសុពលភាពនៃកម្មវិធីដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ដោយសារផលប៉ះពាល់បណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ។

បន្ថែមលើនេះ អង្គប្រជុំបានប្រកាសឱ្យដំណើរការជាផ្លូវការគម្រោង "ការលើកកម្ពស់ភាពប្រកួតប្រជែងរបស់សហគ្រាសនៅកម្ពុជា" ដែលមានរយៈពេល ៤ឆ្នាំ ២០២២-២០២៥ និងមានវិសាលភាពគ្របដណ្ដប់ខេត្តគោលដៅចំនួន ៣ (សៀមរាប បន្ទាយមានជ័យ និងបាត់ដំបងដែលជាខេត្តថ្មី) ។ គម្រោងនេះ ត្រូវបានទទួលការគាំទ្រពីភាគីអាល្លឺម៉ង់ ដែលមានហិរញ្ញប្បទានសរុបចំនួន ៨ លានអឺរ៉ូ ដោយបានប្រកាសក្នុងកិច្ចចរចាស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ក្នុងឆ្នាំ ២០២១ កន្លងមក ។ អង្គប្រជុំ បានសង្ឃឹមយ៉ាងមុតមាំថា គម្រោងនេះនឹងសម្រេចបានសមិទ្ធផលប្រកបដោយជោគជ័យ និងប្រសិទ្ធភាពខ្ពស់ស្របតាមគោលបំណងអភិវឌ្ឍន៍របស់គម្រោងក្នុងការលើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ចដោយការពង្រឹងទីផ្សារប្រកបដោយភាពប្រទាក់ក្រឡា និងជវភាពនៅកម្ពុជា សំដៅបន្តរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍របស់កម្ពុជា ។